# ច្បាប់

## ស្តីពី

## ការធ្វើវិសោធនកម្មមាត្រា ៥១
## នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

# ព្រះរាជក្រម

នស/រកម/០៩៩៩/១១

## យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

អគ្គលេខាធិការដ្ឋាន (ព្រឹទ្ធសភា)
ចូល
លេខ.....1107.............
ថ្ងៃទី 23.09.99 ម៉ោង 11.05
បញ្ជូនទៅ....

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ខែមីនាឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី២ នៃរដ្ឋសភា និង ដែលព្រឹទ្ធសភា បានអនុម័តយល់ស្របតាម លើទំរង់និងគតិនៃច្បាប់នេះទាំងស្រុង នៅថ្ងៃទី ២០ ខែសីហា ឆ្នាំ ១៩៩៩ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី ១ ហើយដែលមាន សេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្តីពី

# ការធ្វើវិសោធនកម្មមាត្រា ៥១

# នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

**មាត្រាតែមួយ.** –

មាត្រា ៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ត្រូវធ្វើវិសោធនកម្មដូចតទៅ :

**មាត្រា ៥១ ថ្មី.** –

ក្នុងករណីដែលមន្ត្រីរាជការណាម្នាក់ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌហើយត្រូវបានព្រះរាជអាជ្ញាសំរេចធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នោះ ទៅប្រធានស្ថាប័នសាមីក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ ។

បើមានការចាប់ខ្លួន ឬការឃាត់ខ្លួន ឬការឃុំខ្លួនជាបណ្តោះអាសន្នលើមន្ត្រីរាជការណាមួយនោះ ព្រះរាជអាជ្ញាឬចៅក្រមមានសមត្ថកិច្ចត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធានស្ថាប័នសាមី ។

ក្នុងករណីដែលបទល្មើសនោះកើតមានក្នុងក្របខ័ណ្ឌនៃការបំពេញការងារសាធារណៈ រដ្ឋត្រូវការពារមន្ត្រីរាជការនោះតាមផ្លូវច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ខែកញ្ញាឆ្នាំ ១៩៩

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីស្តីទី**

**ហត្ថលេខា**

**ស ខេង**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ហត្ថលេខា**

**អ៊ុក វិធុន**

លេខ : ១៩៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ១៩៩៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**